# បុរាណដ្ឋានប្រាសាទភ្នំស្រះខ្ទៅ

បុរាណដ្ឋានប្រាសាទស្រះខ្ទៅ មានទីតាំងស្ថិតនៅលើជួរភ្នំមួយដែលរត់ជួរតាំងពីភ្នំចំប៉ា ភ្នំស្រួច ភ្នំសន្ទុក ភ្នំត្បែង ភ្នំពែនជុំ ហើយស្ថិតនៅក្នុងរដ្ឋបាលភូមិអូរកោះគគីរ ឃុំជ្រាប់ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ ៥គ.ម. ភាគឦសានទីប្រជុំជនឃុំកកោះ។ នៅភ្នំស្រះខ្ទៅ មានរឿងព្រេងមួយដែលនិទានអំពីឈ្មោះរបស់ប្រាសាទនិងភ្នំ ហើយសាច់រឿងសង្ខេបមានដូចតទៅ៖ "កាលពីបុរាណភ្នំស្រះខ្ទៅ មានឈ្មោះថា "ភ្នំតូច" ឯភ្នំសន្ទុកមានឈ្មោះថា "ភ្នំធំ"។ ក្រោយមកព្រះបាទចមពង្សទ្រង់ត្រាស់បង្គាប់ឲ្យពលសេនាគាស់ថ្មជីកស្រះយកទឹកប្រើប្រាស់ និងយកខ្ទៅខ្ទង គ្រំចិញ្ចឹមក្នុងស្រះនេះដើម្បីធ្វើឲ្យទឹកថ្លាឈ្វេងសម្រាប់ព្រះអង្គ និងនាហ្មឺនសព្វមុខមន្ត្រីប្រើប្រាស់ជាប្រចាំ ព្រោះទីនេះបានក្លាយជាទីតាំងព្រះពន្លាជ័យ។ ក្រោយមកទៀត ស្រាប់តែកើតខ្ទៅនៅពេញស្រះ ទោះបីជានាហ្មឺនមន្ត្រីចាប់យកទៅធ្វើម្ហូបយ៉ាងណាក៏មិនចេះអស់ រហូតជាប់ឈ្មោះភ្នំនេះថា "ភ្នំស្រះខ្ទៅ" មកទល់បច្ចុប្បន្ន។ លុះមកដល់ស.វ.ទី៨ មានព្រះមហាក្សត្រមួយអង្គបានកសាងប្រាសាទមួយនៅលើភ្នំនេះដោយមានប្រាសាទធំនៅចំកណ្ដាល និងប្រាសាទតូចៗចំនួនបួនសង់នៅគ្រប់ជ្រុងទាំងបួនទិសដោយមានក្លោងទ្វារនិងជណ្ដើរឡើងពីទិសខាងលិចតាំងពីជើងភ្នំរហូតដល់តួប្រាសាទដែលនៅលើកំពូលភ្នំ"។

រឿងព្រេងនេះទំនងផ្ទុះបញ្ចាំងខ្លះៗអំពីឈ្មោះប្រាសាទ ដ្បិតសាច់រឿងអំពីដើមហេតុនៃការហៅឈ្មោះនេះ គឺមានប្រភពចេញពីស្រះទឹក។ យើងជឿថាប្រភពនៃការហៅឈ្មោះថា "ស្រះខ្ទៅ" នេះទំនងចេញពីស្រះទឹកមួយដែលស្ថិតនៅទិសឦសានប្រាសាទ ដែលជាស្រះមានរៀបថ្មភក់ជុំវិញ។ ចំណែក ពាក្យថា "ខ្ទៅ" ទំនងគេសំដៅលើថ្មនៅជុំវិញមាត់ស្រះដែលគេចោះប្រហោងរាងមូលដូចគូទខ្យង ព្រោះពាក្យថា "ខ្ទៅ" អាចសំដៅលើរាងវង់ ឬរាងដូចគូទខ្យង។ បើក្រឡេកមើលសិលាចារឹកបុរាណវិញ ពាក្យនេះមានប្រើជាឈ្មោះស្រុកមួយនៅសម័យបុរាណដូចឃើញមាននៅក្នុងសិលាចារឹកវត្តដំណាក់ K.420 ដែលរៀបរាប់ថា "ស្រុកខ្ទៅរ"[1]។

ដោយឡែក ប្រាសាទភ្នំស្រះខ្ទៅ ក្នុងពេលបច្ចុប្បន្ននេះ បានបាក់បែកទាំងស្រុងអស់ទៅហើយ នៅសល់តែទួលគរដោយពំនូកឥដ្ឋជាច្រើន ហើយអ្នកស្រុកបានរៀបជាសាទ្បុំមួយនៅពីលើទួលប្រាសាទបាត់ទៅហើយ (រូបលេខ១)។ ម្ល៉ោះហើយ យើងពិបាកក្នុងការដឹងច្បាស់ថា តើប្រាសាទនេះមានតួប៉មសរុបចំនួនប៉ុន្មានឱ្យប្រាកដនោះទេ។ ម្យ៉ាងវិញទៀត នៅសម័យអាណា

[1] Saveros Pou 1992.

និគមបារាំង  ដែលជាពេលជនជាតិមកពីតំបន់អឺរ៉ុបសិក្សានិងចុះបញ្ជីសំណង់បេតិកភណ្ឌរបស់ខ្មែរ គេមិនបានសិក្សាប្រាសាទនេះឡើយ ដូច្នេះហើយ យើងកាន់តែបាត់ពត៌មានបន្ថែមអំពីប្រាសាទ។ ដោយឡែក ប្រសិនបើយើងជឿតាមរឿងព្រេងថាមានតួប៉ម ៥ ពិតមែន វាអាចជាមានតួប៉មកណ្តាលមួយធំ និងតួប៉មតូចៗចំនួន ៤ នៅព័ទ្ធជុំវិញ។ ការដែលគិតបែបនេះ ដ្បិតយល់ថារឿងព្រេងប្រហែលជាកើតឡើងយូរយារ  ហើយបង្កើតជារឿងតាមបរិបទជាក់ស្តែងដែលគាត់មើលឃើញ។ ជួនកាលរឿងព្រេងនេះអាចមានឡើងមុនការបាក់បែកនៃប្រាសាទក៏ថាបាន ប៉ុន្តែ មិនអាចប្រាកដនោះឡើយ ដ្បិតប្រាសាទបានរលំទាំងស្រុងទៅហើយ។

ប្រាសាទស្រះខ្ចៅ មានផ្លូវចូលពីទិសខាងកើត ដែលនៅសងខាងផ្លូវចូលគេមានតម្រៀបជាថ្មបង្គោលរាងផ្កាឈូកដូចឃើញនៅប្រាសាទព្រះវិហារដែរ (រូបលេខ២)។ ទំនៀមនៃការសាងសង់ប្រាសាទ ដោយមានការដាក់បង្គោលដូចជាសីមានៅអមផ្លូវចូលនេះ ទំនងមានតាំងពីសម័យមុនអង្គរ ក្នុងស.វ.ទី៧មកម្ល៉េះ ព្រោះយើងធ្លាប់ឃើញភស្តុតាងតាមរយៈការធ្វើកំណាយនៅមុខតួប៉មកណ្តាលប្រាសាទយាយព័ន្ធដោយអ្នកស្រាវជ្រាវបារាំងកាលពីរវាងទសវត្សរ៍១៩២០ ដោយបានរកឃើញបង្គោលថ្មបាយក្រៀមរាងមូលមានកម្ពស់ទាបៗ ដាក់អមផ្លូវចូលចាប់ពីតួប៉មកណ្តាល S1 រហូតដល់តួប៉ម S2។ ប៉ុន្តែ បង្គោលផ្កាឈូកនៅប្រាសាទភ្នំស្រះខ្ចៅ មានទម្រង់សិល្បៈស្រដៀងបង្គោលផ្កាឈូកនៅស.វ.ទី១០ ឬទី១១ ពោល គឺស្រដៀងបង្គោលផ្កាឈូកនៅប្រាសាទប្រែរូប ប្រាសាទបន្ទាយស្រី និងប្រាសាទព្រះវិហារ[2]។ សព្វថ្ងៃ បង្គោលផ្កាឈូកនៅច្រកទ្វារខាងកើតទាំងនេះ បានដួលអស់ហើយ។

ទោះបីប្រាសាទភ្នំស្រះខ្ចៅបានបាក់បែកទៅហើយក្តី  ប៉ុន្តែវត្ថុសិល្បៈដែលធ្វើឡើងអំពីថ្មភក់មានសេសសល់ច្រើនណាស់ (រូបលេខ៣-៤) តួយ៉ាងដូចជា ផ្តែរទ្វារ ជើងទម្រ បំណែកបដិមាកំពូលប្រាសាទ បំណែកសសរពេជ្រ មេទ្វារ ទ្រនាប់ជណ្តើរ ។ល។ ក្នុងនោះ ផ្តែរទ្វារនៅប្រាសាទភ្នំស្រះខ្ចៅ គេរកឃើញចំនួនពីរផ្ទាំងដែលស្ថិតនៅសម័យកាលផ្សេងៗពីគ្នា។ ផ្តែរទ្វារទីមួយ (រូបលេខ៥) យើងឃើញសិល្បករលម្អដោយក្បាច់បន្ទាត់ធ្នូរាងផ្តេកត្រង់ និងខាងចុងគួចវង់មកខាងលើដូចគូទខ្យង ហើយនៅចុងសងខាងមានចម្លាក់ក្បាលសសរនៅពីក្រោម។ នៅលើបន្ទាត់ធ្នូ មានលម្អជាក្បាច់រាងវង្វង់ចំនួន ៣ ដែលលម្អដោយរូបទេពផ្សេងៗ ប៉ុន្តែសព្វថ្ងៃក្បាច់ត្រង់កន្លែងនេះមានភាពរលុបខ្លាំង យើងមិនអាចមើលដឹងថាជារូបទេពអ្វីឡើយ។ នៅផ្នែកខាងក្រោមនៃផ្តែរ លម្អជារំយោលផ្កា ឬកម្រងមាលាធ្លាស់គ្នា ដែលជាទម្រង់ទូទៅនៃផ្តែរទ្វារសម័យមុនអង្គរ។ ផ្តែរទ្វារនេះ

---

[2] Boisselier 1966.

ទំនងស្ថិតនៅក្នុងសិល្បៈចុងរចនាបថព្រៃក្មេង ដើមរចនាបថកំពង់ព្រះ ដែលមានអាយុកាលនៅរវាងពាក់កណ្ដាលស.វ.ទី៧។ ចំណែក ផ្ដែរទ្វារទីពីរ (រូបលេខ២៦) សិល្បករឆ្លាក់រូបព្រះឥន្ទ្រគង់លើដំរីព្ធរ័ត (ដំរីក្បាលមួយ) នៅចំពាក់កណ្ដាលផ្ដែរ ដែលអមដោយគោពីរកំពុងខាំ លេប ឬខ្ជាក់ក្បាច់បន្ទាត់ធ្នូរាងមូលដូចមែកឈើ ហើយការលម្អផ្សេងទៀតជាចង្វាយក្បាច់អង្គរ។ លក្ខណៈផ្ដែរទ្វារទីពីរនេះ ទំនងជាសិល្បៈនៅស.វ.ទី១០ រចនាបថកោះកេរ ឬរចនាបថប្រែរូប។

ក្រៅអំពីផ្ដែរទ្វារទាំងពីរ វត្ថុសិល្បៈផ្សេងទៀតដែលនៅសល់ ដូចជា សសរពេជ្រ ទ្រនាប់ជណ្ដើរ សុទ្ធសឹងជាសិល្បៈសម័យមុនអង្គរ ក្នុងរចនាបថព្រៃក្មេង ឬកំពង់ព្រះ។ អ្វីដែលពិសេសនៅបុរាណដ្ឋានប្រាសាទភ្នំស្រះខ្ចៅ គេបានរកឃើញផ្ទាំងថ្មគោលសិលាចារឹកមួយផ្ទាំង ដែលចារឹកអក្សរចំនួនបីទិស ហើយសំណេរទាំងនោះមានអាយុកាលពីរសម័យកាលផ្សេងៗគ្នា ពោលគឺផ្ទាំងខាងមុខជាអក្សរចារឹកសម័យមុនអង្គរ ក្នុងស.វ.ទី៧ ហើយអក្សរនៅសងខាងជាសំណេរនៅសម័យអង្គរ ក្នុងស.វ.ទី១០ (រូបលេខ២៧)។ ផ្ទាំងគោលចារឹកនេះ ផ្នែកខាងក្រោមបាត់អស់មួយកំណាត់ ហើយផ្នែកដែលនៅសល់ក៏បានបាក់បែកជាពីរថែមទៀត។ នៅផ្ទៃខាងមុខដែលចារឹកនៅសម័យមុនអង្គរ គេចារជាភាសាសំស្ក្រឹត ហើយបន្ទាត់ដែលនៅសល់មានចំនួន ១១ បន្ទាត់ ស្មើនឹង ១១ស្លោកដូចគ្នា។ ចំណែក អក្សរចារឹកនៅសងខាង គេចារឹកជាភាសាខ្មែរ ដែលមុខទីមួយមាននៅសល់ ២១បន្ទាត់ និងមុខទីពីរមាននៅសល់ ២១បន្ទាត់ដូចគ្នា។ អក្សរចារឹកនៅសម័យមុនអង្គររៀបរាប់អំពីការស្ថាបនា និងគោរពបូជាសិវលិង្គនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ និងមានរៀបរាប់ដល់ការពោលសរសើរព្រះរាជា (រូបលេខ២៨)។ ចំណែក សិលាចារឹកនៅសម័យអង្គរវិញទំនងចុះកាលបរិច្ឆេទមហាសករាជឆ្នាំ៨៤៥ (គ.ស.៩២៣) គឺរៀបរាប់អំពីជង្វាយថ្វាយចំពោះអាទិទេពនៃប្រាសាទ ដែលតំណាងដោយសិវលិង្គ និងរឿងរ៉ាវផ្សេងៗរបស់មន្ត្រីក្នុងស.វ.ទី១០ (រូបលេខ២៩)។

សរុបសេចក្ដីមក បុរាណដ្ឋានប្រាសាទភ្នំស្រះខ្ចៅ មានតឹកតាងផ្នែកប្រវត្តិសាស្ត្រយ៉ាងសម្បើមបម្រើដល់ការងារសិក្សាស្រាវជ្រាវ និងអភិរក្ស បើទោះបីសព្វថ្ងៃប្រាសាទបានបាក់រលំទៅហើយក៏ដោយ។ បុរាណដ្ឋាននេះ អាចចាប់ផ្ដើមឡើងនៅស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ (គ.ស. ៦៥៧ ដល់ ៦៨១) ដែលជាព្រះមហាក្សត្រដ៏សំខាន់នៅសម័យចេនឡា និងជាស្ដេចដែលបានបន្សល់សិលាចារឹកច្រើនជាងគេ ហើយក្រោយមកទៀតគេបានសាងសង់សំណង់បន្ថែមទៀតនៅលើភ្នំស្រះខ្ចៅក្នុងស.វ.ទី១០ មហាសករាជឆ្នាំ៨៤៥ ត្រូវនឹងគ.ស.៩២៣ ពោល គឺត្រូវនឹងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ (គ.ស.៩២១-៩៤១) ឬរជ្ជកាលព្រះបាទហស៌វរ្ម័នទី១ និងព្រះបាទ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ឦសានវរ្ម័នទី២ ដែលទាំងពីរអង្គត្រូវជាបុត្រារបស់ព្រះបាទយសោវរ្ម័នទី១ ឡើងសោយរាជ្យបន្ត បន្ទាប់គ្នាចាប់ពីគ.ស.៩១០ ដល់ ៩២៨។ តាមពត៌មានមួយចំនួនពីសិលាចារឹក យើងអាចសន្និដ្ឋាន ថា បុរាណដ្ឋានប្រាសាទភ្នំស្រះខ្ចៅ សាងឡើងឧទ្ទិសដល់ព្រះឥសូរ ក្នុងព្រហ្មញ្ញសាសនា។

## ឯកសារយោង


**Boisselier, J.**

1966, “*Asie du Sud-Est, Le Cambodge* ”, Tome I, Paris.

**Saveros Pou**

1992, *Dictionnaire Vieux Khmer-Français-Englais*, Paris.




រូបលេខ១៖ បុរាណដ្ឋានប្រាសាទភ្នំស្រះខ្ចៅ ក្នុងពេលបច្ចុប្បន្ន

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៖ បង្គោលសីមារាងផ្កាឈូក នៅច្រកខាងកើតនៃ ប្រាសាទភ្នំស្រះខ្ទៅ



រូបលេខ៣៖ វត្ថុសិល្បៈអំពីថ្មភក់ នៅប្រាសាទភ្នំស្រះខ្ទៅ



រូបលេខ២៤៖ វត្ថុសិល្បៈអំពីថ្មភក់ នៅប្រាសាទភ្នំស្រះខ្មៅ



រូបលេខ២៥៖ ផ្តែទ្វាររចនាបថចុងព្រៃក្មេង ដើមកំពង់ព្រះ ស.វ.ទី៧ នៅប្រាសាទភ្នំស្រះខ្មៅ



រូបលេខ២៦៖ ផ្តែទ្វាររចនាបថកោះកេរ ឬប្រែរូប ស.វ.ទី១០ នៅប្រាសាទភ្នំស្រះខ្មៅ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៧៖ គោលចារឹកអក្សរនៅប្រាសាទភ្នំស្រះខ្ចៅ ដែលបាក់បែកជាពីរកំណាត់



រូបលេខ២៨៖ ក្រដាសផ្តាមសិលាចារឹកសម័យមុនអង្គរ បំណែកទី១ និងទី២ នៅប្រាសាទភ្នំស្រះខ្ចៅ
(ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី





រូបលេខ៩៖ ក្រដាសផ្ដាមសិលាចារឹកសម័យអង្គរ ជ្រុងទី១ និងទី២ នៅប្រាសាទភ្នំស្រះខ្មៅ
(ផ្ដិតដោយ៖ កំ វណ្ណារ៉ា)